# កិច្ចព្រមព្រៀងបម្រុងលើវិសោធនកម្មសម្រាប់ឧក្រិដ្ឋកម្មឈ្លានពាននៅថ្ងៃសុក្រ


**ដោយសាស្ត្រាចារ្យ ដេវិត ហេរ្យហ៊ី**

**ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*


នៅម៉ោង ២:២៥នាទី រសៀលថ្ងៃសុក្រ ទី១១ ខែមិថុនា លោកអគ្គរដ្ឋទូត វេណាវេសឺ ប្រធានអង្គសន្និបាតរបស់ប្រទេសជាភាគី បានចាប់ផ្តើមអង្គប្រជុំដោយសង្ខេបដើម្បីប្រកាសថា នឹងមានការពិភាក្សាផ្លាស់ប្តូរយោបល់មួយជងទៀត និងការចាប់ផ្តើមអង្គប្រជុំសារជាថ្មីនៅម៉ោង៨:៣០នាទីល្ងាចនេះ ។ ជាមួយគ្នានេះ លោកក៏បានប្រគល់ឯកសារពិនិត្យឡើងវិញលើឯកសារក្រៅផ្លូវការរបស់លោកកាលពីថ្ងៃព្រហស្បតិ៍ជូនដល់សមាសភាពចូលរួម ។ នៅក្នុងផ្នែកនេះ ខ្ញុំសូមអធិប្បាយការពិនិត្យឡើងវិញ បម្រុងលើឯកសារក្រៅផ្លូវការនេះដែលមានរៀបរាប់នៅក្នុងផ្នែកទីបីនៃអត្ថបទរបស់ខ្ញុំ ។

ការពិនិត្យឡើងវិញកាលពីរសៀលថ្ងៃសុក្រ ពាក់ព័ន្ធតែពីមាត្រា១៥ក និង១៥ខថ្មីដែលបង្កើតឲ្យមានជាលក្ខន្តិកៈសម្រាប់ឧក្រិដ្ឋកម្មឈ្លានពានប៉ុណ្ណោះ ។ ការពិនិត្យឡើងវិញបម្រុងទីមួយនេះគឺត្រួតពិនិត្យលើមាត្រា១២ក (ប្រទេសជាភាគី និងសេចក្តីសម្រេចផ្ទាល់របស់ព្រះរាជអាជ្ញា) ហើយលុបចោលដំណោះស្រាយទីមួយចេញពីផ្នែកទី៤ដែលថា (គ្មានការស៊ើបអង្កេតឡើយ លុះត្រាតែវាមានចារនៅក្នុងវង់ក្រចកកាលពីម្សិលមិញ នោះក្រុមប្រឹក្សាសន្តិសុខអនុម័តជំពូក៧នៃកិច្ចព្រមព្រៀងរបស់ក្រុមប្រឹក្សាសន្តិសុខ ដោយធ្វើការស្នើសុំឲ្យព្រះរាជអាជ្ញាបន្តដំណើរការស៊ើបអង្កេត លើឧក្រិដ្ឋកម្មឈ្លានពាន) ។ ដំណោះស្រាយទី១ តែងតែក្លាយជាជម្រើសដែលសមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខផ្តល់អាទិភាព ពីព្រោះដំណោះស្រាយនេះធ្វើការគូសបញ្ជាក់ពីអំណាចផ្តាច់មុខរបស់ក្រុមប្រឹក្សាសន្តិសុខលើបញ្ហាកំណត់អំពើឈ្លានពាន ។ យ៉ាងណាមិញ ដូចដែលបានពន្យល់បកស្រាយនៅក្នុងអត្ថបទមុន គឺថាគម្រោងស្តីពីឥទ្ធិពលអំណាចនេះមិនសូវទាក់ទាញការគាំទ្រប៉ុន្មានទេពីសំណាក់ប្រទេសជាភាគីភាគច្រើន ។

ការប្រើប្រាស់ពាក្យថ្មីធ្វើការសំអាងលើដំណោះស្រាយទី២កាលពីម្សិលមិញ ដោយរួមមានគុណសម្បត្តិគួរឲ្យចាប់អារម្មណ៍ស្តីពីតួនាទី«រារាំង»របស់ក្រុមប្រឹក្សាសន្តិសុខ ។ ការពិនិត្យឡើងវិញបម្រុងនេះ មានសេចក្តីថា : «ប្រសិនបើគ្មានសេចក្តីសម្រេចត្រូវបានធ្វើឡើងក្នុងរយៈពេល៦ខែក្រោយពីថ្ងៃកំណត់ទេ

នោះ ព្រះរាជអាជ្ញាអាចនឹងបន្តដំណើរការស៊ើបអង្កេតទាក់ទងនឹងឧក្រិដ្ឋកម្មឈ្លានពាន ក្នុងករណីដែលអង្គភាពអង្គបុរេជំនុំជម្រះបានចេញសេចក្តីអនុញ្ញាតដំណើរការស៊ើបអង្កេត ទាក់ទងនឹងឧក្រិដ្ឋកម្មឈ្លានពានដោយស្របតាមនីតិវិធីដែលមានចែងនៅក្នុងមាត្រា១៥ ហើយនិងករណីដែលក្រុមប្រឹក្សាសន្តិសុខមិនទាន់បានសម្រេចឲ្យស្របតាមមាត្រា១៦» ។

គម្រោងដំណោះស្រាយទី២ក្រៅផ្លូវការកាលពីថ្ងៃព្រហស្បតិ៍កន្លងទៅនេះបានធ្វើការដាក់ពាក្យ «រារាំង» នៅក្នុងវង់ក្រចកយោងតាមក្រុមប្រឹក្សាសន្តិសុខ ប៉ុន្តែមិនបានគូសបញ្ជាក់ថាដំណោះស្រាយនេះនឹងត្រូវតែក្លាយជាកិច្ចព្រមព្រៀងមួយដែលតម្រូវទៅតាមលក្ខខណ្ឌរបស់មាត្រា១៦នៃលក្ខខណ្ឌក្រុងរ៉ូមទេ ។ ដោយធ្វើការគូសបញ្ជាក់លើមាត្រា១៦ លោកអគ្គរដ្ឋទូត វេណាវេសឺ ហាក់បីដូចជាកំពុងតែធ្វើឲ្យអំណាចគ្រប់គ្រងលើដំណើរការរបស់ក្រុមប្រឹក្សាសន្តិសុខនេះកាន់តែមានឥទ្ធិពលចុះខ្សោយ ពីព្រោះថាមាត្រា១៦បានចែងពីរយៈពេលកំណត់មួយឆ្នាំដោយចុងបញ្ចប់នៃអាណត្តិនេះ ក្រុមប្រឹក្សាសន្តិសុខត្រូវតែបោះឆ្នោត ដើម្បីបន្តការពន្យារពេលស៊ើបអង្កេតរបស់តុលាការលើឧក្រិដ្ឋកម្មឈ្លានពានសារជាថ្មីម្តងទៀត ។ ហើយបើសិនអាក់ខានមិនបានបោះឆ្នោតនោះ ដំណើរការស៊ើបអង្កេតអាចនឹងបន្តធ្វើទៅមុខទៀត ដោយមានសេចក្តីអនុញ្ញាតពីអង្គភាពអង្គបុរេជំនុំជម្រះ ។ នីតិវិធីនោះបានដាក់បន្ទុកប្រចាំឆ្នាំឲ្យក្រុមប្រឹក្សាសន្តិសុខ ដែលជាបន្ទុកមួយដែលក្រុមប្រឹក្សាសន្តិសុខចង់ ឬមិនចង់ប្រឈមមុខដោះស្រាយកាលៈទេសៈដាក់លាក់ណាមួយដែលស្តីពីបញ្ហាឈ្លានពាននៅរៀងរាល់ចុងឆ្នាំឡើយ ។ ខ្ញុំអាចយល់បានថាហេតុអ្វីបានជា គម្រោងនេះអាចទាក់ទាញចំណាប់អារម្មណ៍របស់ជនដែលមានជាប់ពាក់ព័ន្ធនឹងអំណាចរបស់ក្រុមប្រឹក្សាសន្តិសុខនេះ ។ ប៉ុន្តែខ្ញុំក៏យល់ថាហេតុអ្វីបានជាគម្រោងនេះធ្វើឲ្យមានការព្រួយបារម្ភដល់សមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខអំពីភាពចាំបាច់ប្រចាំឆ្នាំក្នុងការវិលទៅពិភាក្សាពីគម្រោង នេះ ហើយធ្វើការបោះឆ្នោត ប្រសិនបើបញ្ហាគម្រោងនេះនៅតែបន្តជាកង្វល់ដល់ក្រុមប្រឹក្សា ។

យ៉ាងណាមិញ នេះគឺជាគម្រោងកិច្ចព្រមព្រៀងដែលនឹងត្រូវតែធ្វើការពិចារណាឲ្យបានហ្មត់ចត់ ។ គម្រោងនេះនឹងរក្សាសារសំខាន់របស់ក្រុមប្រឹក្សាសន្តិសុខលើការឈ្លានពាន ហើយអនុញ្ញាតឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិធ្វើការងារទាក់ទងនឹងបញ្ហាការឈ្លានពាននេះបន្តទៀត ប្រសិនបើក្រុមប្រឹក្សាសម្រេចមិនធ្វើការអនុម័តកិច្ចព្រមព្រៀងលើមាត្រា១៦ ។ ការពិនិត្យឡើងវិញបម្រុង បន្ទាប់លើផ្នែកទី៤នៃមាត្រា១៥កធ្វើការដាក់បញ្ចូលបញ្ញត្តិថ្មីមួយគឺផ្នែកទី៤កដែលចែងថា : «តុលាការអាចនឹងមិនអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មឈ្លានពានស្របតាមមាត្រា១៥កបានទេ លុះត្រាប្រទេសជាភាគីធ្វើ

សេចក្តីសម្រេចមិនលើសពីឆ្នាំ២០១៧» ។ នេះគឺជាដំណោះ ស្រាយដែលមានរយៈពេលដាក់លាក់មួយ គឺ៧ឆ្នាំសម្រាប់ការស៊ើបអង្កេតលើឧក្រិដ្ឋកម្មឈ្លានពានយោងតាមសេចក្តីសម្រេចរបស់ប្រទេសជាភាគី និងការស៊ើបអង្កេតដោយផ្ទាល់របស់ព្រះរាជអាជ្ញា ។ ដូច្នេះ ប្រទេសជាភាគីត្រូវតែធ្វើការប្រជុំពិភាក្សា ដើម្បីសម្រេចថា ត្រូវដាក់យុត្តាធិការរបស់តុលាការលើការឈ្លានពាននៅពេលណាដោយផ្អែកលើ សេចក្តីសម្រេចដែលមានចែងនៅក្នុងមាត្រា១៣ក និង ១៣គ ទាំងអស់នេះ ។

លក្ខណៈសមហេតុផលរបស់ការពិនិត្យឡើងវិញនេះអាចកើតចេញពីឥទ្ធិពលរបស់មាត្រា១២៤ដែលជា សេចក្តីសម្រេចមិនចូលរួមពាក់ព័ន្ធនឹងបញ្ហាឧក្រិដ្ឋកម្មសង្គ្រាមដែលមានសម្រាប់ប្រទេសជាភាគីក្រោយ ពីការផ្តល់សច្ចាប័នរយៈពេល៧ឆ្នាំ ។ ការពិនិត្យនេះក៏មានប្រភពដើមចេញពីមាត្រា១២៤(១) ដែល តម្រូវឲ្យមានការប្រជុំពិនិត្យឡើងវិញក្នុងរយៈពេល៧ឆ្នាំបន្ទាប់ពីការដាក់លក្ខន្តិកៈក្រុងរ៉ូម ចូលជាធរមាន (សំដៅលើការប្រជុំនៅទីក្រុងកាំប៉ាឡា នេះតែម្តង ទោះបីជាវាមានរយៈពេលស្ទើរតែ៨ឆ្នាំ ក្រោយពី ការដាក់ចូលជាធរមានកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ក៏ដោយ) ។

បន្ថែមលើនេះ ការពិនិត្យឡើងវិញថ្មីជាច្រើនធ្វើការរួមបញ្ចូលគម្រោងសារជាថ្មីមួយស្តីពីសិទ្ធិរបស់ ប្រទេសជាភាគីក្នុងការចេញសេចក្តីប្រកាសមួយទាក់ទិននឹងការមិនទទួលយកយុត្តាធិការរបស់តុលាការ លើឧក្រិដ្ឋកម្មឈ្លានពាន ។ ខ្ញុំបានអានការសរសេរដែលមានចែងនៅក្នុងការពិនិត្យឡើងវិញបម្រុងនេះ ដែលមានន័យថា សេចក្តីប្រកាសពីការមិនទទួលយកយុត្តាធិការរបស់តុលាការនេះត្រូវតែរក្សាទុក ជាមួយនឹងអ្នកកាន់កាប់បញ្ជីឯកសារមុននឹងការប្រព្រឹត្តឧក្រិដ្ឋកម្មឈ្លានពាន មិនមែនក្រោយពេលដែល ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងនោះទេ ។ ប៉ុន្តែ អ្នកខ្លះអាចយល់ថា«ប្រទេសជាភាគីបានប្រកាសទទួល យកយុត្តាធិការនេះពីមុនរួចហើយ» ដែលមានន័យថាការប្រកាសកាលពីមុនរបស់តុលាការលើយុត្តា ធិការលើឧក្រិដ្ឋកម្មឈ្លានពានណាមួយកំពុងតែប្រឈមមុខនឹងបញ្ហា ។ ខ្ញុំមិនជឿថាការយល់ឃើញដូច ខាងលើនេះត្រឹមត្រូវទេ ។

ការពិនិត្យឡើងវិញថ្មី ធ្វើការជំនួសឲ្យប្រយោគចុងក្រោយរបស់ផ្នែកទី១ខនៃឯកសារក្រៅផ្លូវការកាលពី ថ្ងៃព្រហស្បតិ៍ជាមួយនឹងការចែងដូចតទៅ ៖ «ក្រោយពីរយៈពេល៧ឆ្នាំ សេចក្តីប្រកាសបែបនេះ ត្រូវ តែផុតកំណត់ ប្រសិនបើការប្រកាសនេះមិនត្រូវបានគូសបញ្ជាក់ឲ្យច្បាស់លាស់ ។ សេចក្តីប្រកាសនេះ អាចនឹងត្រូវបានដកចេញគ្រប់ពេលវេលាទាំងអស់» ។ ដូច្នេះ នេះគឺជាការពិនិត្យដ៏សំខាន់មួយ ពីព្រោះ

វានឹងតម្រូវឲ្យមានការប្រកាសសារជាថ្មីពីការមិនទទួលយកយុត្តាធិការរបស់តុលាការ រៀងរាល់៧ឆ្នាំម្តង ដើម្បីសម្រេចឲ្យមានសេចក្តីប្រកាសជាផ្លូវការមួយស្តីពីការមិនទទួលយកយុត្តាធិការរបស់តុលាការ ដែលត្រូវតែរក្សាទុកនឹងអ្នកកាន់កាប់បញ្ជីឯកសារ រៀងរាល់៧ឆ្នាំ ។ រឿងដែលគួរឲ្យអាម៉ាស់អាចនឹងជះឥទ្ធិពលបានយ៉ាងងាយមកលើប្រទេសជាភាគី ដែលលាក់បាំងការពិតរបស់ខ្លួនទាក់ទងនឹងបញ្ហាឧក្រិដ្ឋកម្មឈ្លានពាន ។ ប្រយោគទីពីរចែងពីការពិតដែលថាសេចក្តីប្រកាសអាចនឹងត្រូវបានដកចេញដោយខ្លួនឯងគ្រប់ពេលវេលាទាំងអស់ ។ Gone គឺជាពាក្យមិនច្បាស់លាស់ដែលជម្រុញឲ្យប្រទេសជាភាគីធ្វើការពិចារណាក្នុងការចេញសេចក្តីប្រកាស ក្នុងរយៈពេល៣ឆ្នាំ និងពិចារណាលើគោលគំនិតដកសេចក្តីប្រកាសចេញ ។

ចុងក្រោយបង្អស់ មានការពិនិត្យឡើងវិញបម្រុងមួយលើមាត្រា១៥ខដែលធ្វើការគ្រប់គ្រងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខយោងតាមមាត្រា១៣(ខ) និងរបស់តុលាការទាក់ទិននឹងការឈ្លានពាន ។ ការប្រើប្រាស់ពាក្យថ្មីនឹងពិនិត្យផ្នែកទី២ឡើងវិញដើម្បីឲ្យមានន័យថា “តុលាការអាចនឹងអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មឈ្លានពានស្របតាមមាត្រា១៥ខ ក្នុងរយៈពេល៧ឆ្នាំបន្ទាប់ពីការដាក់វិសោធនកម្មលើឧក្រិដ្ឋកម្មឈ្លានពានចូលជាធរមាន ប្រសិនបើប្រទេសជាភាគីមិនធ្វើសេចក្តីសម្រេច” ។ ការធ្វើបែបនេះហាក់បីដូចជាតម្រូវថា ផ្នែកទី២នៃការពិនិត្យកាលពីម្សិលមិញត្រូវបានពិនិត្យឡើងវិញជាបន្តបន្ទាប់ដើម្បីឲ្យរយៈពេល៧ឆ្នាំចាប់ផ្តើមម្តងទៀត ក្រោយពីការដាក់វិសោធនកម្មដោយការប្រជុំពិនិត្យឡើងវិញចូលជាធរមាន មានន័យថានៅឆ្នាំ២០១៧ ប្រសិនបើសេចក្តីអនុញ្ញាតនឹងទទួលបាននាពេលបច្ចុប្បន្ននេះ ។ គម្រោងនេះអាចនឹងត្រូវបានផ្លាស់ប្តូរ ប្រសិនបើប្រទេសជាភាគីសម្រេចដូច្នេះក្នុងពេលអនាគត ។ គ្មានការណែនាំពីការតម្រូវឲ្យប្រទេសជាភាគីយ៉ាងហោចណាស់៣០ធ្វើការផ្តល់សច្ចាប័នលើវិសោធនកម្មដូចដែលបានស្នើសុំកាលពីម្សិលមិញឡើយ (អមជាមួយនឹងរយៈពេល៥ឆ្នាំលើយុត្តាធិការក្រៅផ្លូវការ) ។ យ៉ាងណាមិញ មានការថតវីឌីអូមួយលើទំព័រដែលចែងថា “ការផ្លាស់ប្តូរជាបន្តបន្ទាប់អាចនឹងចាំបាច់ត្រូវតែធ្វើឡើងដើម្បីចេញសេចក្តីព្រៀងលើមាត្រា១៥ខ កថាខណ្ឌ២” ។ វាមិនទាន់ច្បាស់លាស់នៅឡើយទេថា តើពាក្យដើមមួយចំនួន(ដូចជាបញ្ហាផ្តល់សច្ចាប័នរបស់ប្រទេសជាភាគីចំនួន៣០) នឹងត្រូវរក្សាទុកដដែលឬយ៉ាងណានោះទេ ។ យើងនឹងត្រូវតែរង់ចាំមើលថាតើបញ្ហានេះត្រូវបានពន្យល់បកស្រាយនៅម៉ោង៨:៣០នាទីល្ងាចថ្ងៃនេះដោយរបៀបណា ។

ចំណុចទាំងអស់នេះហើយដែលអ្វីៗទាំងអស់កំពុងតែដំណើរការនាពេលនេះ ខណៈពេលដែលព្រះអាទិត្យចាប់ផ្តើមលិចនៅទីក្រុងកាំប៉ាឡា ។ ខ្ញុំប្រហែលជាមិនអាចផ្ញើអត្ថបទចេញម្តងទៀតទេរហូតដល់ថ្ងៃសៅរ៍ ថាតើការប្រើប្រាស់ពាក្យចុងក្រោយត្រូវបានអនុម័ត ឬក៏ការចរចានេះប្រឈមមុខនឹងការបរាជ័យខ្លះៗ ហើយសន្និបាតនេះបញ្ចប់ទៅដោយមិនសម្រេចអ្វីទាំងអស់ឬយ៉ាងណា ។ យើងត្រូវតែរង់ចាំមើលថាមានអ្វីនឹងកើតឡើងក្នុងរយៈពេលពីរបីម៉ោងខាងមុខ ។